# កម្មវិធីឃ្លាំមើលសវនាការសាលាក្តីខ្មែរក្រហម

សំណុំរឿង០០២-០២ ▪ របាយការណ៍លេខ ២០ ▪ សវនាការលើកស្តុតាង ▪ សប្តាហ៍ទី១៧ ▪ ថ្ងៃទី២៥ -២៨ ឧសភា ឆ្នាំ២០១៥



ករណីរបស់ជនជាប់ចោទលោក **នួន ជា** និង លោក **ខៀវ សំផន**

**Asian International Justice Initiative (AIJI), a project of East-West Center and the WSD Handa Center for Human Rights and International Justice at Stanford University (previously known as the UC Berkeley War Crimes Studies Center)**

# របាយការណ៍សង្ខេបប្រចាំសប្តាហ៍ លេខ ២០

នាសប្តាហ៍នេះ អង្គជំនុំជម្រះសាលាដំបូង បានបន្តស្តាប់សក្ខីកម្មដែលពាក់ព័ន្ធទៅនឹងបទពិសោធន៍របស់កម្មករដែលធ្វើការនៅការដ្ឋានសាងសង់ទំនប់១មករា ក្នុងស្រុកបារាយ៍ ខេត្តកំពង់ធំ។ សាក្សីចំនួនមួយរូប និង ដើមបណ្តឹងរដ្ឋប្បវេណីចំនួនពីររូប បានបង្ហាញខ្លួនដើម្បីផ្តល់សក្ខីកម្មស្តីពីបទសោធន៍របស់ពួកគាត់នៅការដ្ឋានទំនប់នោះ។ អ្នកស្រី **មាស ឡាយហួ** អ្នកស្រី **ហ៊ុន សុថានី** និងអ្នកស្រី **អ៊ុន រ៉ន** ពួកគាត់បាននិយាយពីលក្ខខណ្ឌរស់នៅយ៉ាងអាក្រក់ និងលក្ខខណ្ឌការងារដ៏លំបាកលំបិននៅការដ្ឋាន។ ពួកគាត់បានពិភាក្សាពីការភ័យខ្លាច និងសេចក្តីរងទុក្ខវេទនានៅពេលនោះ ហើយពួកគាត់ក៏បានផ្តល់ជាឧទាហរណ៍ជាច្រើនផងដែរ ស្តីពីការប្រព្រឹត្តយ៉ាងឃោរឃៅដោយអាជ្ញាធរខ្មែរក្រហម ដូចដែលពួកខ្មែរក្រហមបានធ្វើការតាមដានស្វែងរក “ខ្មាំង” របស់របបនេះ។ អង្គជំនុំជម្រះ ក៏បានផ្តល់ឱកាសឲ្យភាគីទាំងអស់ផ្តល់នូវទឡ្ហីករណ៍ផ្ទាល់មាត់ស្តីពីការប្រើប្រាស់ជាប្រក្រតីនូវភស្តុតាងដែលបានមកពីទារុណកម្ម។ អង្គជំនុំជម្រះក៏បានធ្វើការប្រកាសសម្រេចដាក់បញ្ចូលខ្មែរក្រោមជាក្រុមគោលដៅទៅក្នុងបទចោទប្រកាន់ក្នុងសំណុំរឿង០០២ វគ្គទី២ ផងដែរ។ បញ្ហាផ្លូវច្បាប់ទាំងនេះ ក៏ដូចជាសក្ខីកម្មរបស់សាក្សីទាំងបីរូបនេះ ត្រូវបានធ្វើការសង្ខេប និងពិភាក្សាក្នុងរបាយការណ៍ខាងក្រោមនេះដូចតទៅ។

* របាយការណ៍នេះ ត្រូវបានសរសេរដោយ លៀ ហ៊ូបើ (Lea Huber), លី ហួតផេង, ដាញ៉ែល ម៉ាតថេស៍ (Daniel Mattes), តាយ លីណា, ថោង វិច្ឆិកា, ភីនីឡូភី វ៉ាន់ ធូល (Penelope Van Tuyl), កាធើរីន វើសសេល (Katherine Vessels), និង វង្ស ឧត្តម ដែលជាផ្នែកមួយនៃកម្មវិធីឃ្លាំមើលសវនាការសាលាក្ដីខ្មែរក្រហម និង ការផ្សព្វផ្សាយតាមសហគមន៍របស់អង្គការគម្រោងផ្ដួចផ្ដើមយុត្តិធម៌អន្តរជាតិប្រចាំអាស៊ី (AIJI)។ AIJI គឺជាគម្រោងកិច្ចសហប្រតិបត្តិការរវាងមជ្ឈមណ្ឌលបស្ចិម-បូព៌ា (East-West Center) នៅអូណូឡូឡូ (Honolulu) និងមជ្ឈមណ្ឌល ដាប់ប៊ែលយូ.អេស.ឌី ហាន់ដា សម្រាប់សិទ្ធិមនុស្ស និងយុត្តិធម៌ អន្តរជាតិ (WSD Handa Center) ដែលកាលពីមុន ត្រូវបានគេស្គាល់ថាជា មជ្ឈមណ្ឌលសិក្សាអំពីឧក្រិដ្ឋកម្មសង្គ្រាម ប៊ែកឃ្លី (Berkeley War Crime Study Center)។ ចាប់តាំងពីឆ្នាំ២០០៣មក មជ្ឈមណ្ឌលទាំងពីរនេះ បានកំពុងធ្វើកិច្ចសហប្រតិបត្តិការគ្នាលើគម្រោងជាច្រើន ដែលពាក់ព័ន្ធនឹងការបង្កើតការផ្ដួចផ្ដើមយុត្តិធម៌ និងកម្មវិធីកសាងសមត្ថភាពនានា ក្នុងវិស័យសិទ្ធិមនុស្សប្រចាំតំបន់អាស៊ីអាគ្នេយ៍នេះ។

EAST-WEST CENTER

AIJI TRIAL MONITORING

WSDHANDACENTER
FOR HUMAN RIGHTS & INTERNATIONAL JUSTICE
Stanford University